# វគ្គ

## បងសារ៉ាយ

ដោយបងប្រុសរបស់ណានីនត្រូវទៅបំពេញការងារនៅឆ្ងាយផ្ទះ យើងបានបងសារ៉ាយដែលជាមនុស្សស្មោះត្រង់ស្គាល់គ្នាជាមួយគ្រួសារណានីននៅស្រុកកំណើតមកនៅបានជាគ្នា គ្រប់គ្នាទុកគាត់ដូចជាញាតិម្នាក់ ហើយមិនដែលសម្តីធំតូច ឬបានអ្វីហូបរំលងចោលគាត់ឡើយ។

រស់នៅយូរៗទៅ បងសារ៉ាយស្រាប់តែលេចចេញអាការៈប្លែកៗហាក់មានអ្វីមួយលាក់កំបាំងនឹងពួកយើង។ គាត់ចេះតែរអ៊ូសុំទៅផ្ទះវិញម្តងជាពីរដង ទោះបីជាម្តាយក្មេកខ្ញុំទទូចសុំដឹងហេតុផលយ៉ាងណាក៏ដោយ។

លុះដល់គាត់ចេះតែអង្គុយសំកុកមិនព្រមចង់និយាយស្តី ហើយបើនិយាយទន្ទេញតែពីរឿងចង់វិលទៅស្រុកវិញ ភរិយាខ្ញុំកើតចិត្តធុញថប់ ក៏យល់ព្រមឱ្យគាត់ទៅទាំងចិត្តមិនចង់ ព្រោះនាងមានផ្ទៃពោះ ៦ ខែហើយ។

យប់នោះបន្ទាប់ពីបានការព្រមព្រៀង បងសារ៉ាយបានរៀបចំសម្ភារៈរបស់គាត់ហាក់អំណរសប្បាយជាពន់ពេកមិនមានចិត្តស្តាយស្រណោះអ្វីដូចពួកយើងដែលជាម្ចាស់ផ្ទះបន្តិចណាសោះឡើយ។ ប្រការនេះធ្វើឱ្យភរិយាខ្ញុំឆ្អែតចិត្តលែងចង់ស្តីរកគាត់សោះតែម្តង។

នៅពេលពាក់កណ្តាលអធ្រាតយប់ដដែលនោះ ស្រាប់តែគ្រប់គ្នាក្នុងផ្ទះត្រូវភ្ញាក់កន្ត្រាក់ឡើងពីដំណេកទាំងរន្ធត់ ព្រោះសម្រែកចេញមកគ្រលួចពីបន្ទប់ចុងខាងក្រោយគេដែលជាទីកន្លែងបងសារ៉ាយតែងស្នាក់អាស្រ័យចាប់ពីពេលគាត់ចូលមកក្នុងគ្រួសារយើង។

«មានរឿងអី?»

ពុក និងម្តាយក្មេកខ្ញុំចេញទៅដល់មុនគេ បន្ទាប់មកគឺខ្ញុំ រីឯភរិយារបស់ខ្ញុំឈរសម្លឹងមកពីមាត់ទ្វារបន្ទប់ ព្រោះតែនាងពោះធំធ្ងន់ផង នាងនៅខឹងបងសារ៉ាយផង។

បងសារ៉ាយយំគគ្រុកចង្កុលទៅកាច់ជ្រុងផ្ទះក្បែរបង្អួចបែរទៅទិសខាងត្បូង ជាកន្លែងដែលពុកក្មេកខ្ញុំបានធ្វើធ្នើរមួយវែងប្រវែងបណ្តោយប្រមាណជា ៤ ម៉ែត្រ និងទទឹងកន្លះម៉ែត្រទុកដាក់របររបស់ចាស់ៗដែលមិនសូវប្រើ។ កន្លែងនោះងងឹតស្រពេចស្រពិលពឹងតែភ្លើងជះមកពីខាងមុខ ព្រោះគ្មានអំពូលថ្មីជាយូរមកហើយ។

លើកគ្រាលឥដ្ឋ មានកែវទឹកមួយបែកខ្ចាយ បង្ហាញថាបងសារ៉ាយប្រហែលជាស្រេកទឹក ហើយក្រោកមកដួសទឹកហូប គាត់ដើរកាត់ទីនេះ រួចឃើញនូវអ្វីម្យ៉ាងដែលគាត់មិនអាចទទួលយកបាន។

«ខ្មោចអង្គុយនៅលើកៅអី!»

កៅអីផ្តៅចាស់សល់មួយត្រូវបានទុកចោលនៅកាច់ជ្រុងយូរណាស់មកហើយ។ នៅលើនោះ គ្មានអ្នកណាទាំងអស់ តែបងសារ៉ាយនិយាយពាក្យដដែលៗថាមានគេអង្គុយលងគាត់នៅទីនោះ។

«ខ្មោចស្រីមកតាមខ្ញុំយូរហើយ ខ្ញុំមិនចង់នៅទៀត ដោយសាររឿងហ្នឹង! វាតែងតែមកគោះទ្វារ លាត់មុង ឈរចុងជើង វាឆ្លងកាត់ចុះឡើងក្នុងផ្ទះនេះ ខ្ញុំទៅហើយ ខ្ញុំទ្រាំមិនបានទេ!»

បងសារ៉ាយបែកញើសជោកពេញមុខ ដៃជើងញ័រចំប្រប់ តាមមើលគាត់ពុំមែននិយាយលេងទេ។

ម្ដាយក្មេកខ្ញុំចូលទៅក្បែរ ហើយហៅគាត់ឱ្យថយមកបន្ទប់ខាងមុខវិញ គាត់នៅតែមិនស្វាង បន្តនិយាយស្ដីតក់ស្លុតជាមួយប្រធានបទដដែលៗ។ គាត់រៀបរាប់ថា៖

«មុននេះ ខ្ញុំចុះទៅចាក់ទឹកមកហូបថ្នាំ ព្រោះគេងមិនបានសោះ! ដំបូង ខ្ញុំមានអារម្មណ៍ថាមាននរណាម្នាក់កំពុងដើរតាមខ្ញុំ ហើយទាត់ជើងខ្ញុំឱ្យដួល តែពេលខ្ញុំងាកទៅមើល គ្មាននរណាសោះ! ខ្ញុំដើរមកទៀត ស្រាប់តែមានដៃច្រានឱ្យខ្ញុំផ្កាប់មុខដួលទាំងជំហរតែម្ដង។

ថាចប់ បងសារ៉ាយក៏សន្លប់បាត់ស្មារតី ធ្វើឱ្យអ្នកផ្ទះខំកោសរឹតគាត់ទម្រាំបានធូរមកវិញ តែគាត់ឡើងកម្ដៅខ្លាំងណាស់។ ព្រឹកឡើងដោយគាត់មិនអាចបកទៅស្រុកបាន យើងក៏អញ្ជើញពេទ្យក្បែរផ្ទះឱ្យមកជួយតាមដាន និងដាក់សេរ៉ូម។

អ្នកជិតខាងដែលរាប់អានគាត់ បានឡើងចុះមកសួរសុខទុក្ខ ព្រោះថាបងសារ៉ាយ គាត់ជាមនុស្សរួសរាយគេស្រលាញ់រាប់អានគ្រប់គ្នា។

ក្នុងចំណោមនោះ មីងទូចជាអ្នកជិតខាងម្នាក់ដែលឧស្សាហ៍បណ្ដើរគ្នាទៅផ្សារជាមួយបងសារ៉ាយ គាត់ឡើងមកញឹកជាងគេ។

រសៀលបន្តិច គាត់មកលេងជាថ្មីដោយធ្វើទឹកសណ្ដែកមកផ្ញើហូបផង។ ពេលស្ងាត់មនុស្ស គាត់ក៏ដាច់ចិត្តកេះម្ដាយក្មេកខ្ញុំសួរថា៖

«មីង ខ្ញុំសុំសួរមីងតាមត្រង់! មួយរយៈនេះ មើលពីផ្ទះខ្ញុំមក ឃើញផ្ទះមីងមានអ្នកមកនៅជួយការងារបន្ថែមហ្មែន? គាត់ឈ្មោះអី អាឡូវម៉េចក៏មិនឃើញ? គាត់មកពីស្រុកជាមួយសារ៉ាយហ្មែន? ហើយថ្ងៃនេះម៉េចមិនឃើញ?»

ម្ដាយខ្ញុំងាកមកមើលមុខកូនៗ ព្រោះយើងនៅតែគ្នាប៉ុណ្ណឹងនាក់ មានមនុស្សពីណាមក?

ឃើញគាត់ស្ងាត់ មីងទូចប្រាប់បន្ថែម៖

«ឃើញដើរត្រសងជាមួយសារ៉ាយច្រើនថ្ងៃមកហើយ!»

ម្ដាយក្មេកខ្ញុំឮហើយ ហាក់ភ័យរវេីក្មេកមករកបងសារ៉ាយដែលដេកដាក់សេរ៉ូមនៅឡើយ។ បងសារ៉ាយ ហាក់មិនសូវស្រួលក្នុងអារម្មណ៍ដែរ ពេលឮបែបនេះ គាត់ប្រកែកភ្លាម៖

«មានហ្មាមីង? ខ្ញុំមានដើរជាមួយអ្នកណា? មីងឯងកុំមកថែមឱ្យភ័យមើល៍? ឃើញអង្កាល់?»

ឮហើយ មីងទូចធ្វើភ្នែកភាំងលៃងមាត់ សម្លឹងពួកយើងម្ដងម្នាក់ហាក់ស្លុត។ អាការៈគាត់បញ្ជាក់ថាគាត់មិនបាននិយាយពន្លើសទេ គ្រាន់តែពេលនេះគាត់ក៏ទទួលអារម្មណ៍ដូចយើងដែរ។

ខ្ញុំនឹកឃើញភ្លាមដល់ករណីខ្លួនឯងកាលពីប៉ុន្មានឆ្នាំមុនដែលដើរទៅណាមកណាមានព្រាយស្រីមួយមកតាមលងបន្លាចម្ដងឃើញខ្លួនឯង ម្ដងមិត្តភ័ក្តិឃើញ ហើយចុងក្រោយត្រូវមីងលក់សាំងឃើញខ្ញុំឱបស្រីទាំងថ្ងៃទៀត?

«ស្រី ឬប្រុស ទូច? ហើយឃើញយូរឬនៅ? មើលច្រឡំដឹង?»

ម្ដាយក្មេកខ្ញុំសួរកាត់ផ្ដាច់អារម្មណ៍របស់ខ្ញុំឱ្យវិលមកវិញ។ ពួកយើងទាំងអស់គ្នាសម្លឹងឆ្ពោះទៅរកមីងទូចហាក់រង់ចាំចម្លើយដូចគាត់ជាផ្ទាំងស៊ីប។

«មនុស្សស្រី ឃើញដើរត្រសងក្បែរៗសារ៉ាយមិនថាពេលស្រោចផ្កា ហាលខោអាវ បោសផ្ទះ!»

គ្រប់គ្នានៅស្ងៀមស្ងាត់សម្លឹងមុខគ្នាទៅវិញទៅមក។

ខ្ញុំវិញគិតចុះគិតឡើងម្នាក់ឯងពីស្ថានភាពនេះ។ រង់ចាំដល់មីងទូចចេញទៅវិញបាត់ ខ្ញុំក៏ចូលទៅលួចសួរបងសារ៉ាយថា៖

«បងឯងដែលច្រឡំហូបសាច់ឆ្កែដែរ?»

គាត់បដិសេធដាច់ខាត៖

«អត់ទេចា! បងមិនដែលទេ បងមិនចេះផឹកស៊ីអីផ្ដេសផ្ដាសទេ!»

ខ្ញុំនៅស្ងៀមគិតចុះឡើងទាំងសម្លឹងតបទៅគាត់គ្រលួងៗ។ ខ្ញុំយល់ថា គាត់ក៏ដឹងពីស្ថានភាពរបស់គាត់ដែរដែលមកជួបរឿងប្លែកៗអស់នេះ។ ពួកយើងពិគ្រោះគ្នាទាំងព្រលប់នោះថាត្រូវអញ្ជើញគ្រូផ្លូវងងឹតមកមើលទៀតហើយ ថាតើមានរឿងអ្វីកើតឡើងចំពោះបងសារ៉ាយ ពិសេសចង់ដឹងថាមានរឿងអ្វីកើតឡើងចំពោះគាត់ ស្រមោលដែលបន្លាចគាត់ដល់ថ្នាក់លែងចង់នៅផ្ទះនេះ និងមនុស្សស្រីដែលមីងទូចនិយាយជាករណីតែមួយ ឬផ្សេងគ្នា យើងពិតជាត្រូវការដឹងឱ្យបាន?

បងសារ៉ាយខ្សោយខ្លួនទៅណាមិនបាន គាត់ក៏បានខលហៅម្ដាយគាត់ឱ្យមកពីស្រុក។ ខ្ញុំដឹងថាគាត់ភ័យខ្លួនខ្លាំងហើយ។

ខ្ញុំ និងម្ដាយក្មេកខ្ញុំព្យាយាមលួងគាត់ជានិច្ច តែចិត្តយើងពិតជាបារម្ភដូចគ្នា ព្រោះច្រើនឆ្នាំមកហើយ យើងមិនដែលភ្លេចរឿងដើមឈើចម្លាមនោះឡើយ។

យើងបានការយល់ព្រមគ្រប់គ្នា ហើយខ្ញុំក៏ខលទៅសួរយោបល់តាសច្ចា។

«លោកតា! មានបងម្នាក់មកនៅនឹងខ្ញុំ អាឡូវគាត់ចេញរឿងភ័យប្លែកៗ ហើយមានអ្នកជិតខាងគេមើលឃើញពីផ្ទះគេមកថា មានស្រីចម្លែកម្នាក់ដើរតាមគាត់រហូត មិនថាគាត់កំពុងរវល់ធ្វើអីក៏ដោយ លោកតា ផ្ទះយើងគ្មានមនុស្សស្រីណាផ្សេងមកនៅសោះ! អាចទេអាចព្រាយដើមឈើនោះត្រឡប់មករករឿងវិញ?»

មិនទាន់បានសួរនាំអ្វីច្រើនក្រៅពីឈ្មោះ និងខែឆ្នាំនោះទេ ស្រាប់តែលោកគ្រូដ៏ពូកែម្នាក់នោះស្រែកគំហកមកខ្ញុំវិញថា៖

«មីនោះវាយករបស់គេ! ម្ចាស់គេតាមមកទារ បើវាមិនសារភាព អញមិនទៅមើលឱ្យទេ!»

ខ្ញុំឮហើយ ក៏ចូលមកក្នុងផ្ទះវិញ លបខ្សឹបសួរបងសារ៉ាយតែពីរនាក់ទាំងខឹងទាំងជា៖

«អាចារ្យគន់មើលនៅនុះ! គាត់ឆ្លើយមកថា បងឯងយករបស់គេ បានជាគេមកតាមទាមទារមិនទៅណា!»

គាត់សម្លឹងខ្ញុំភ្លឹះៗមិននិយាយអ្វី តែគាត់ស្លេកស្លាំងមុខធ្វើឱ្យចិត្តខ្ញុំកាន់តែតប់ប្រមល់។ ខ្ញុំធ្វើក្រញូវនិយាយនឹងគាត់បន្ថែម៖

«បងឯងធ្លាប់ឮរឿងខ្ញុំពីមុនហើយមែនអត់? ព្រាយមួយតាមខ្ញុំមិនព្រមទៅណាទាំងអស់រហូតដល់ម៉ែរកគ្រូពីរបីទម្រាំបណ្ដេញទៅផុត! ឥឡូវតាសច្ចាគាត់មិនព្រមមកធ្វើពិធីឱ្យទេ បើសិនជាបងឯងមិនសារភាព!»

ថាហើយ ខ្ញុំចុះមកដីតាំងចិត្តថាឈប់រវល់រឿងគាត់ ឱ្យតែគាត់ជា ចេញទៅស្រុកវិញផុតៗចុះ។ យប់នោះ ឃើញម្ដាយកូនបងសារ៉ាយជជែកគ្នាខ្សឹបខ្សៀវអ៊ុះៗរហូតដល់ពេលថ្មើរណា ក៏មិនដឹង។

មិននឹកស្មានថា ហេតុតែភ័យពេកសឹងលោះព្រលឹងទៅហើយ ចុងក្រោយបងសារ៉ាយព្រមសារភាព ដោយឱ្យម៉ែគាត់មករកខ្ញុំទាំងព្រហាមស្រាងៗ។

«ថាអ៊ុំ សារ៉ាយវាមិនបានលួចរបស់គេទេ តែវារកឃើញរបស់មួយនៅក្រោមផ្ទះ ពេលវាទៅរើកាយរបស់ចាស់ៗយកចេញទៅចោល!»

ខ្ញុំឮមិនស្មើនឹងភ្ញាក់ផ្អើល ពេលឃើញវត្ថុនោះឡើយ។ ម្ដាយរបស់គាត់យកបង្ហាញឱ្យខ្ញុំមើលនូវកងដៃបុរាណដ៏ធំមួយដែលមានពណ៌ឈាមជ្រូកក្រមៅខ្លះលឿងខ្លះ។ ពិនិត្យចុះឡើង វាមានសណ្ឋានដូចជាមាសសុទ្ធដែលត្រូវបានកប់ក្នុងដី ឬត្រូវនឹងសារធាតុអ្វីសឹកខាងក្រៅ សមជាវត្ថុបុរាណជាយូរយារ ទាំងទំហំវា ទាំងពណ៌សម្បុរ។

ខ្ញុំយកវាទៅបង្ហាញអ្នកផ្ទះ។

ពុកក្មេកខ្ញុំឃើញកាលណា ក៏ស្រែកឡើងថា៖

«កងហ្នឹងហើយ វានៅក្នុងកេសដែលពុកបាត់រកមិនឃើញ!»

ចាស់ៗជឿថា វត្ថុកប់ក្នុងដីភាគច្រើនវាអាចផ្លាស់ទីចេញពីកន្លែងដើមដោយសារដំណើររបស់ផែនដី អ៊ីចឹងហើយឪពុកក្មេកខ្ញុំកើតចិត្តសង្ឃឹមភ្លាមថា គាត់នឹងអាចរកឃើញកេសនោះវិញ។

«ឯងឃើញកងដៃនេះពីកន្លែងណា សារ៉ាយ?»

ពុកខ្ញុំដេញសួរទាំងភ័យអរលាយគ្នា។

បងសារ៉ាយបាននាំគ្រួសារយើងទៅក្រោមផ្ទះ ហើយបង្ហាញកន្លែងដែលគាត់អះអាងថារកឃើញកងដៃនោះ ពេលគាត់សម្អាតវត្ថុចាស់ៗ។

ទីនោះជាអតីតសម្បុកកញ្ច្រែង អង្រុត ល្អី កញ្ជើចាស់ៗដែលត្រូវបានទុកឱ្យសឹករេចរឹលចោល។ ពេលនេះ វាស្អាតធេង ដោយសារតែបងសារ៉ាយរៀបរយយកទៅចោល។ ពុកក្មេកខ្ញុំយកចបមក

ហើយបបួលខ្ញុំកាប់គាស់រកមើលទៀត ក្រែងឃើញដានហឹបដែលគាត់បានបាត់ជាយូរមកហើយនោះ។

រហូតដល់ថ្ងៃត្រង់ខ្ពស់ យើងក៏ជីកចំហឹបចាស់នោះមែន។

អស្ចារ្យណាស់! គ្រប់យ៉ាងមិនខុសអ្វីពីពាក្យពុកក្មេកខ្ញុំធ្លាប់អះអាងប្រាប់តាសច្ចាទេ។ ក្នុងហឹបនោះមានទាំងអាវស្បៃ គ្រឿងអលង្ការ និងត្បូងបុរាណខ្ចាយរប៉ាត់រប៉ាយច្រើនពណ៌ប្រទ្បាក់ដីកាន់។

«យើងគិតបែបម៉េចនឹងរបស់អស់នេះ?»

ខ្ញុំសួរទៅពុកក្មេកខ្ញុំ ចិត្តមួយបារម្ភខ្លាចគាត់នៅលោភចង់ទុកជាទ្រព្យផ្ទាល់ខ្លួន តែតាមពិតទៅ ទុក្ខសោកកាលពីអតីតកាល គឺកាលដែលកូនប្រុសច្បងគាត់ធ្លាប់ដេកកន្ទេលឈឺមើលមិនត្រូវ គាត់លែងហ៊ានជាមួយវត្ថុបុរាណអស់ទាំងនេះ។

«ផ្ញើទុកនឹងលោក ឬយកទៅទុកនឹងតាសច្ចាចុះ ឱ្យចប់ៗរឿង!»

ពុកក្មេកខ្ញុំគាត់សម្រេចចិត្តបែបនេះ ធ្វើឱ្យគ្រប់គ្នាធូរទ្រូងជាខ្លាំង។ ខ្ញុំទទួលភារកិច្ចទាក់ទងទៅកាន់តាសច្ចាភ្លាម តែពេលនោះគាត់ឆ្លើយមកវិញដាច់ណាត់ថា មិនទទួល។

យើងសួររកវិធី គាត់ឱ្យរកថ្ងៃល្អមួយបញ្ជូនចេញពីផ្ទះ ថ្ងៃល្អដែលគាត់រកបានគឺបន្ទាប់ពីនោះពីរថ្ងៃប៉ុណ្ណោះ យើងក៏ត្រូវឱបហឹបនោះទៅរកគាត់ដល់ផ្ទះ។ គ្នាយើងមានបងសារ៉ាយ ម្តាយគាត់ ខ្ញុំ និងពុកក្មេកខ្ញុំ។

ក្នុងចិត្តខ្ញុំ ខ្ញុំតែងតែជឿថា ដរាបណាហឹបនោះនៅនឹងទីកន្លែងណា ស្រីម្នាក់ដែលបងសារ៉ាយឃើញច្បាស់ជាតាមកិតជាប់ជានិច្ច ដូច្នេះខ្ញុំមិនហ៊ានឱបវាទេ ទុកភារៈនេះទៅឱពុកក្មេកខ្ញុំ។

ពិធីបរព្រៃបញ្ជូនអ្នកថែរក្សាទ្រព្យឱ្យចាកចេញលើកនេះ គឺគាត់មិនបានបង្គាប់អ្វីច្រើន ក្រៅពីឱ្យរកកំណាត់លឿងផ្អេះមួយផ្ទាំងមកចងបិទហឹបនោះយ៉ាងមាំ ហើយបាញ់ទឹកអប់ឱ្យមុត ព្រមទាំងចងថ្មឱ្យធ្ងន់ផ្តោបពីសងខាង។

មុនពេលចេញពីផ្ទះគាត់ តាសច្ចាបញ្ជាក់សួរម្តង ហើយម្តងទៀតថា៖

«របស់ក្នុងនេះគ្រប់ចំនួនឱ្យគេវិញអស់ហើយឬនៅ?»

ខ្ញុំមិនមានយោបល់អ្វីចំពោះរឿងនេះសោះតែម្តង។

ពុកក្មេកខ្ញុំក៏គាត់កប់ឃោបល់ ព្រោះក៏ដូចជាចាំមិនបានដែរថាតើរបស់របរទាំងអស់មានអ្វីខ្លះ។ ដូច្នេះតាសច្ចាក៏បង្គាប់ថា៖

«ពេលខ្ញុំសួរអ្វីត្រូវឆ្លើយថា អើ ជានិច្ច!»

គាត់ឱ្យពួកយើងចេញទៅរកកន្លែងណាដែលមានខ្សែទឹកហូរលឿន ដូច្នេះពួកយើងក៏ចេញដំណើរទៅមាត់ទន្លេផ្នែកខាងលើក្នុងមូលដ្ឋានខណ្ឌឬស្សីកែវ ហើយជួលទូកបងប្អូនខ្មែរឥស្លាមចេញទៅធ្វើពិធីនៅកណ្ដាលទន្លេ។

ពុកក្មេកខ្ញុំឱបហឹបអង្គុយនៅក្បាលទូកក្បែរតាសច្ចា ចំណែកខ្ញុំ និងបងសារ៉ាយ និងម្ដាយគាត់នៅកណ្ដាល។

យុវជនខ្មែរឥស្លាមម្នាក់ជាអ្នកបញ្ជាទូក។

តាសច្ចាសូត្រធម៌គាត់ច្រើនចប់ណាស់ ទម្រាំគាត់ទម្លាក់ចេកមួយស្និតធំទៅក្នុងទឹក ហើយបោះធូបទៅបីសរសៃទាំងកំពុងឆេះហុយនោះទៅដែរ។ បន្ទាប់មក គាត់ងាកមកសួរពួកយើងថា ហឹបនេះមានគ្រប់របស់ដែរ?

ពួកយើងឆ្លើយព្រមគ្នាថា «អើ»។ គាត់សួរដដែលៗបីដង យើងក៏នាំគ្នាឆ្លើយដដែលៗបីដងដែរ មុនពេលគាត់ស៊ុញ៉ូភ្នែកឱ្យពុកខ្ញុំរុញហឹបទម្លាក់ទឹក។

ដោយមានថ្មសណ្ដូន ហឹបចាប់ផ្ដើមលិចតិចៗ តាសច្ចាក៏ស្រែកច្រៀងឡើងថា៖

«នាងអើយនាងលក្ខណ៍ ក្លិនក្រអូបច្បាស់ នាងតាមឱ្យទាន់ នាងកុំងាកក្រោយ កុំភ័យកុំភាន់ នាងតាមឱ្យទាន់ របស់នាងហើយ»

រួចរាល់ គាត់បង្គាប់ឱ្យបងសារ៉ាយវិលទៅផ្ទះនិមន្តព្រះសង្ឃលើករាសីជាការស្រេច។

ចាប់ពីពេលនោះមក បងសារ៉ាយក៏វិលទៅនៅឯស្រុកជាមួយម្ដាយគាត់វិញសុខសាន្តរហូតតរៀងមក លែងមានអ្នកណាតាមលងបន្លាចទៀត។ ភរិយាខ្ញុំសម្រាលបានកូនស្រីម្នាក់ ហើយយើងមិនមានកូនទីពីរទៀតនៅឡើយ។

ច្រើនឆ្នាំក្រោយមក គ្រួសារយើងបានទទួលដំណឹងលោកតាអាចារ្យសច្ចាមានជំងឺជាទម្ងន់ ខ្ញុំបានឆ្លៀតពេលទៅលេងគាត់ម្ដងជាពីរដង មុនពេលគាត់ទទួលមរណភាពដោយជរាពាធ។

ក្រោយមកពេលកូនទីពីរខ្ញុំមកទំពោះណានីន ខ្ញុំស្រាប់តែឡើងតំណែងថ្មីមានបៀវត្សល្អ ព្រមទាំងផ្លាស់ទៅទទួលបន្ទុកជាអ្នកដឹកនាំនៅខេត្តបាត់ដំបង។

គ្រួសារខ្ញុំគឺ ខ្ញុំ ណានីន និងកូនក្នុងពោះផងបានរើមកនៅផ្ទះសម្រាប់មន្ត្រីនៅបាត់ដំបង ចំណែកកូនស្រីទីមួយនៅរៀននៅភ្នំពេញ។

**វគ្គ**

**ផ្ទះដីឡូត៍**

ពេលរើមកនៅភ្លាមៗ ខ្ញុំយកចិត្តទុកដាក់ពិនិត្យពិច័យបរិវេណផ្ទះនោះល្អិតល្អន់ ព្រោះគ្រួសារយើងមានជំនឿលើរឿងភូតព្វ ហុងស៊ុយ អរូបិយនេះបំផុត បន្ទាប់ពីបានឆ្លងកាត់រឿងមកច្រើនគួរសម។

វាជាប្រភេទផ្ទះល្វែងតូចល្មមមួយតែនៅដាច់ពីគេលើដីឡូស្រស់បំព្រងទៅដោយដំណាំ តែខ្ញុំបានពិនិត្យច្បាស់លាស់ណាថា គ្មានដើមឈើណាមួយមានរាងដូចចម្លាមទេ។ ផ្ទះនេះមានលក្ខណៈធម្មតា ព្រោះជាសំណង់សង់ថ្មី ហើយកែបន្ថែមច្រើនដងដោយម្ចាស់គេ។ ពេលនេះ ខាងក្រុមហ៊ុនបានជួលមកឱ្យខ្ញុំរស់នៅ ដោយសារនៅពីក្រោយផ្ទះក្បែររបងមានរោងមួយធំស្រាប់ អាចធ្វើជាឃ្លាំងដាក់អីវ៉ាន់របស់ក្រុមហ៊ុនទៀត ប្រសិនថ្ងៃណាមួយយើងត្រូវការ។

ដំបូង ខ្ញុំចង់ចូលទៅពិនិត្យឃ្លាំងខាងក្រោយនោះដែរ ប៉ុន្តែដោយសារវាត្រូវបានគេចាក់សោជិត ឯខ្ញុំក៏រវល់ពីមួយថ្ងៃទៅមួយថ្ងៃផង ចេះតែហីមករាប់ខែ ម្យ៉ាងខ្ញុំមិនដែលនឹកខ្វល់ថាមានអ្វីចម្លែកនៅទីនោះសោះឡើយដោយជញ្ជាំងរោងនោះធ្វើពីដែកចម្រឹងប្រហោងមិនពិបាកសម្លឹងទៅបរិវេណខាងក្នុងផង។ ថៅហ្វាយនាយនៅនេះរកបានឆ្កែមួយមកឱ្យខ្ញុំ។ វាឈ្មោះអាលិច មកនៅជួយមើលចាំផ្ទះ ព្រោះដីក៏ធំ។

ប្រពន្ធខ្ញុំនាងរកផ្ទះទេវតា និងជំនាងមកដាក់តាំងតាមប្រពៃណី និងឧស្សាហ៍អុជធូបទៀនរាល់សីលមិនដែលរំលងឡើយ។

ខ្ញុំរក្សាអនាម័យបោសជម្រះ និងបាញ់ទឹកសម្អាត ប្រាថ្នាសេចក្តីសុខយ៉ាងជាប់លាប់ ហើយមិនដែលមានគំនិតបៀតបៀន ឬនិយាយស្តីទ្រគោះប្រមាថកាតទាននាំកាត់រាសីឡើយ។

ទោះយ៉ាងណា រឿងចម្លែកនៅតែកើតមានឡើងមកលើគ្រួសារខ្ញុំទាល់តែបាន...

នៅថ្ងៃសៅរ៍ចុងសប្តាហ៍មួយ បងឌីនបានឡើងមកពីស្រុក ហើយនាំប្រពន្ធគាត់មកសម្រាន្ត លេងជុំនៅទីនេះ។ បំណងរបស់គាត់ គឺឱ្យខ្ញុំជូនទៅលេងហួសដល់ប៉ៃលិន តែមិនទាន់បានទៅ។

រសៀលនេះ ភរិយាខ្ញុំ និងប្រពន្ធបងឌីនបានស្រុះស្រួលគ្នាចេញទៅដើរផ្សារទិញអីវ៉ាន់ចំណីត្រីសាច់មកធ្វើជប់លៀងល្ងាចជុំគ្នាម្តង ចំណែកបងឌីនគាត់ហួសចេញទៅលេងសួរសុខទុក្ខផ្ទះអ្នកស្គាល់គ្នាជាមួយគាត់។

ខណៈពេលដែលពួកគេចេញទៅអស់ ខ្ញុំមិនមានអ្វីធ្វើ ក្រៅពីនៅអង្គុយម្នាក់ឯងងប់ជាមួយYouTubeតាមកុំព្យូទ័ររបស់ខ្ញុំអស់ពេលជាយូររហូតដល់ហត់នឿយ និងភ្លេចខ្លួន។

អាលិចឆ្កែខ្ញុំ វាដេកលេងក្បែរនោះដូចជាមិត្តកំដរបន្ថែមភាពកក់ក្តៅដល់ខ្ញុំដែរ។

យូរម្តងពេលខ្ញុំចាប់អារម្មណ៍ថាស្ងាត់ ហើយខ្លាចតិចៗ ខ្ញុំក៏ងាកទៅរកវា វាដេកធ្វើភ្នែកភ្លឹះៗ ដាក់ក្បាលរាបទៅផ្ទាល់នឹងកម្រាលស៊ីម៉ងត៍។

ខ្ញុំងាកមកលេងហ្វេសប៊ុក ស្រាប់តែឃើញរូបបិសាចដែលគេនឹងបញ្ចាំងក្នុងរោងកុន។

អារម្មណ៍ព្រឺព្រួចយ៉ាងចម្លែក បង្ខំឱ្យខ្ញុំចុចរូបនោះបិទ ហើយប្រមូលអារម្មណ៍មកបរិយាកាសជុំវិញខ្លួន។

ស្នូរអ្វីមួយលាន់មកតាមខ្យល់។

វាជាសំឡេងកុបៗ លាន់ឡើងមិនខ្លាំង តែមិនឈប់ឈរ។

ខ្ញុំចម្លែកចិត្តផ្ទៀងស្តាប់។

សម្គាល់យូរៗទៅ វាដូចជាវត្ថុរឹងមួយកំពុងបុកកុបៗទៅលើឥដ្ឋ។

ឬអាចថា អ្នកណាម្នាក់កាន់ឈើច្រត់កំពុងដើរចុះឡើងក្បែរៗនេះក៏ថាបាន។

ប៉ុន្តែ??? តើមានជនពិការឯណាមកនៅក្នុងផ្ទះនេះ?

ខ្ញុំគិតហើយ ក៏បង្អង់ដកដៃចេញពី Key។

សត្វឆ្កែរបស់ខ្ញុំវិញក៏មានប្រតិកម្មហាក់បីដូចជាវាបានឮសំឡេងចម្លែកនោះដូចគ្នាដែរ។

អាលិចស្ទុះងើបក្បាល សម្លឹងរំពៃ។

ខ្ញុំរាវរកដបទឹកចង់យកមកក្រេប តែខ្ញុំឃើញអាលិចងាកបែរសម្លឹងឆ្ពោះទៅបង្អួចបន្ទប់បាយ។

ហេតុអ្វីវាគិតដូចខ្ញុំម្ល៉េះថាសំឡេងលាន់ចេញមកពីម្តុំនោះ?

ប្រការនេះធ្វើឱ្យខ្ញុំលែងនឹកស្រេកទឹក។

មេឃមិនទាន់ងងឹត ខ្ញុំក៏មិនទាន់បើកភ្លើងឡើងដែរ។

ខ្ញុំរង់ចាំមើលអាលិចរហូតដល់វាស្ទុះក្រោក ហើយសម្លក់ទៅបង្អួចផ្ទះបាយដោយព្រុសរន្ថាន់។

ពេលដែលសុនខធ្វើឫកពាដ៏ស្លន់ស្លោបែបចម្លែក ចិត្តខ្ញុំកាន់តែចម្លែកជាង។

វាដូចមិនដែលអ៊ុចឹងទេ។

សកម្មភាពវាធ្វើឱ្យខ្ញុំសម្លឹងទៅកាន់ទីនោះដូចគ្នា។ មានអ្នកណានៅផ្ទះបាយទៅ?

ខ្ញុំបុកពោះ ហើយខលទៅបងឌីន។

ទូរសព្ទមិនមានសេវាសោះ។

ខ្ញុំក្រោកឡើងពីកៅអី ហើយគិតថាឈានទៅក្រៅផ្ទះខលទៀត។

តែអាលិចកាន់តែព្រុស។

ខ្ញុំងាកទៅសម្លឹងវាចំហមាត់ផ្លុង។

«ព្រុសស្អីហ្នឹងអ្ហា?»

អស់ពីព្រុស វាងាកក្បាលឃើតៗមករកខ្ញុំហាក់កំពុងព្យាយាមប្រាប់ពីអ្វីមួយដល់ខ្ញុំ។

ដោយខ្ញុំនៅសម្លឹងវាផ្ទាំង វាក៏ដូរទិសដៅបោលចូលទៅក្រោមបង្អួចបន្ទប់បាយនោះ ចាប់ផ្ដើមលូ។

ឆ្កែលូ??????

រោមខ្ញុំបះ!

ខ្ញុំមិនចង់ឱ្យអ្នកណាដឹងថាខ្ញុំជាមនុស្សខ្លាចដល់ថ្នាក់ហ្នឹង តែខ្ញុំពិតជាកំពុងខ្លាច។

ភ្នែកផ្ដើមសម្លឹងទៅទីនោះ ចិត្តពេញទៅដោយក្ដីពិភាល់ កាយវិការកាន់តែប្រុង។

អាលិចវាខំតោងផង អឺផង ហើយគោលដៅភ្នែកវា គឺកំណត់ទៅរកអ្វីម្យ៉ាងនៅខាងក្រោយបង្អួចនោះ។ ខ្ញុំមិនសូវយល់ពីកាយវិការសត្វទេ តែចាស់ៗតែងនិយាយថា ឆ្កែលូព្រោះវាឃើញខ្មោច។

ហេតុអ្វីវាមកលូថ្មើរណេះ?

ទោះជាយើងមិនងាយគិតយល់ពីអ្វីដែលសត្វកំពុងតែចង់បង្ហាញប្រាប់តាមរយៈសំឡេងលូនោះ តែខ្ញុំដឹង អាលិចបានដឹងថាមានអ្វីនៅក្នុងបន្ទប់បាយនោះច្បាស់ហើយ គឺវាដឹង ហើយសំខាន់ វាហាក់ដូចជាមិនចូលចិត្តអ្វីមួយនោះផងដឹង បានជាវាលូ។

បន្ទាប់ពីទ្រឹងមួយខណៈ ខ្ញុំព្យាយាមធ្វើពើដូចជាគ្មានខ្វល់អ្វី ហើយហួចហៅឆ្កែឱ្យបកក្រោយមកវិញ។

ទោះយ៉ាងណា វាមិនព្រមត្រឡប់មកវិញសោះ គ្រាន់តែវាងាកមកមើលខ្ញុំ ហើយបែរត្រឡប់ទៅគោលដៅដដែលទាំងលូផង ព្រុសផង។

ខ្ញុំលែងដឹងហើយថាតើស្នូរឈើច្រត់នៅឮទៀតឬអត់ទេ ព្រោះផ្តោតអារម្មណ៍តែលើអាលិច។

រំពេចនោះ វាស្រាប់តែស្ទុះស្ទាងើបមុខសម្លឹងឆ្ពោះទៅរបងផ្ទះខាងឆ្វេង ហើយចាប់ផ្តើមក្រោកប្រដេញ។

ខ្ញុំក៏ម្ទឹម្ទារត់តាមទាំងពិនិត្យអ្នកដែលនៅនឹងមុខវា។

វាហាក់កំពុងរត់ប្រដេញតាមអ្នកណាម្នាក់។ គេនោះរត់ពីមុខវាស្លេវទៅឃ្លាំងខាងក្រោយ តែខ្ញុំហាក់យល់ថាជាមនុស្សស្រីដែលមានកម្ពស់ខ្ពស់ស្រាវ សក់វែងខ្មៅអង្កាញ់ វែងដល់ចង្កេះ។

រំពេចនោះ ខ្ញុំប្រាប់ខ្លួនឯងថា អ្នកសក់វែងនោះជាខ្មោច ព្រោះនាងហាក់មិនបានរត់ តែបែរជាអាចរសាត់ខ្លួនសន្សឹមៗទៅខាងក្រោយផ្ទះតម្រង់រោងចាស់ជាឃ្លាំងនោះ។

ខ្ញុំភ័យស្លុត បេះដូងលោតច្រាលភ្លឹបសឹងថប់ប្រព័ន្ធដង្ហើម ខ្លួនប្រាណបែកញើសស្អិត។

ខ្ញុំខំហាស្រែកឃាត់ឆ្កែកុំឱ្យដេញតាម តែហាចេញបានតែម្លូបៗគ្មានសំឡេង។

កណ្តាលស្ថានភាពភ័យតក់ស្លុត ខ្ញុំឃើញឃ្លាំងចាស់នោះត្រូវបានគេរុះចោលរាបដល់ដី។ តើគេរុះពីពេលណា? អ្នកណាធ្វើ? បងឌីន? ម៉េចខ្ញុំមិនដឹង នៅមិននៅគេរុះឃ្លាំងនោះចោលធ្វើអី?

ខ្ញុំងឺងើ...

ចំណែកម្នាក់ស្រីនោះលែងរសាត់លឿនទៀត ហើយនាងអណ្តែតយឺតៗចូលទៅក្នុងបរិវេណរោងនោះក្រោមភាពគាំងតក់ស្លុតរបស់ខ្ញុំ ហើយរលាយបាត់។

«ខ្មោចៗ ជួយផងខ្មោច!»

ខ្ញុំដឹងថាខ្លួនឯងប្រឹងស្រែកៗដដែលៗនេះទាំងបម្រះននៀល ហើយនេះទំនងជាក្នុងយល់សប្តិ តែហេតុអ្វីបានជាខ្ញុំមិនភ្ញាក់ដឹងខ្លួនមកវិញសោះ? មិនត្រឹមតែប៉ុណ្ណោះ ខ្លួនខ្ញុំហាក់បីដូចជារសាត់បណ្តើរៗទៅរកនាងទៀត?

វរហើយ! ខ្ញុំពិតជារំកិលទាំងដែលខ្លួនឯងមិនបានធ្វើចលនា?

ខ្ញុំស្បថថាលើកនេះ ដឹងខ្លួនវិញ ខ្ញុំត្រូវតែរកគេមកមើលឃ្លាំងនោះ ហើយសូត្រមន្តចេញ។

ទោះយ៉ាងណា វាប្រហែលជាយឺតពេលហើយ?

ពេលនេះ ខ្ញុំមិនត្រឹមរំកិលទេ តែខ្ញុំបានឃើញខ្លួនឯងមកទើរនៅក្នុងកន្លែងមួយដែលចម្លែកមិនដឹងទិសតំបន់ណាឱ្យច្បាស់ទៀត។

អាលិចបាត់ស្រមោលហើយ វាទៅណាហើយ ម៉េចវាមិនមកតាមព្រុសការពារម្ចាស់ដូចរាល់ដង?

ឱខ្ញុំអើយ ពេលណាចេញបានពីសុបិនអស់នេះ?

អ្វីដែលត្រូវដឹង គឺថាតើខ្លួនឯងនេះកំពុងអណ្តែតមកដល់ទីណា។

ខ្ញុំសម្លឹងជុំវិញខ្លួន។

វាគួរតែជាកសិដ្ឋានដ៏សែនកខ្វក់មួយ គ្មានសត្វ មានជីវិតទេ តែមានចំបើង និងដីប្រឡាក់សើមខ្មៅស្រមក។

សំឡេងថ្ងូរគួរឱ្យព្រឺព្រួចមួយខ្សែយ៉ាងតម្អូញវែងលាន់មករំខានសែនរំខាន កាន់តែគេចមិនរវល់កាន់តែតែឮច្បាស់ កាន់តែទប់ត្រចៀក កាន់តែចូលកៀក។

ទោះបីក្នុងកាលៈទេសៈបែបណា មនុស្សយើងនៅតែមានញាណដឹង។ ចំហាយត្រជាក់មួយ កំពុងរំកិលយឺតៗចូលមកពីក្រោយខ្នងខ្ញុំពិតណាស់។

នោះជាស្អី?

បងឌីនគួរតែត្រឡប់ផ្ទះមកជួយខ្ញុំ។

វរទៀត គឺពន្លឺខៀវស្រាលៗមកពីចំហៀងកន្ទុយភ្នែកស្តាំ។ សរសៃសក់បក់រវិចៗអមមកជាមួយស្រមោលនោះផងធ្វើឱ្យរាងកាយខ្ញុំភ័យញាក់។

ទោះបីគ្រប់យ៉ាងលែងគ្រប់គ្រងបាន តែបំណាច់នឹងដួល ខ្ញុំត្រូវដឹងដែរថា នោះជាអ្វី មានរឿងអ្វីកំពុងកើតឡើងចំពោះខ្លួនឯង? ដូច្នេះ ខ្ញុំបែរក្រោយយ៉ាងរហ័សរកចម្លើយ។

សូម្បីតែខ្លួនឯងក៏មិនដឹងថាខ្ញុំអាចមានប្រតិកម្មងាកក្រោយយ៉ាងរហ័សកម្រិតនេះ?

ស្ត្រីម្នាក់ពិតណាស់ នាងកំពុងឈរនៅពីក្រោយខ្នងខ្ញុំ ហើយពេលនេះនាងនៅប្រឈមនឹងខ្ញុំមិនដល់ម៉ែត្រផងទេ។

រូបរាងនាងធ្វើឱ្យខ្ញុំដួលត្មោល ព្រោះជង្គង់ទន់គ្មានកម្លាំងឈរបន្ត។

នារីនេះស្លៀកពាក់ជាកូនក្រមុំបុរាណស្អេកស្កះទៅដោយរំយោលផ្លែកក្រហម និងត្បូងធំៗលើអលង្ការស្រោបខ្លួននាង តែខ្ញុំរកនឹកមិនឃើញទេថាជាជនជាតិអ្វី គ្រាន់តែស្ថានភាពនាងខ្ញុំទទួលអារម្មន៍ថា នាងហាក់កំពុងរៀបការ។

ក្បាលរបស់នាងគ្របដណ្តប់ដោយស្បៃចរបាប់ ហើយនាងគ្មានមុខទេ ងងឹតស្លុបមើលមិនឃើញតែម្តង។

នាងលើកម្រាមដៃស្តាំទាំងប្រាំដែលមានពាក់ចិញ្ចៀនយ៉ាងធំមួយមកចង្អុលមុខខ្ញុំ តែមើលបន្តិចទៅមិនសមថាចង្អុលខឹង តែវាជាការសុំជំនួយ ឬអ្វីទេ។

«ខ្ញុំមិនដឹងអីទេ! ខ្ញុំមិនបានរុះរោងរបស់នាងទេ! ចេញទៅ ថយចេញពីខ្ញុំ!»

ខ្ញុំស្រែកម្តបៗគ្មានសំឡេង គ្មានកម្លាំងយំ គ្មានទឹកភ្នែកមាត់សំណើម តែក្នុងចិត្តវិញ ខ្ញុំសូត្រធម៌ហើយរម្លឹកនឹកគុណម៉ែឪបែរបន់មិនឈប់ឈរ។

នារីនោះស្រាប់តែដកដៃចេញវិញ ហើយរសាត់ថយក្រោយគ្រឹបៗ។

ខ្ញុំដឹងខ្លួនភ្ញាក់ឡើងវិញព្រឹប ឃើញខ្លួនឯងកំពុងដេកទាំងអង្គុយក្បែរកំព្យូទ័រ ហើយបរិយាកាសជុំវិញងងឹតស្លុបទាំងអស់។

ទោះបីយ៉ាងណា បានចាកចេញពីសុបិនឬស្សានោះហើយ។

បេះដូងលោតបង្ហូសៗ ហើយខ្យល់ដកដង្ហើមរបស់ខ្ញុំលាន់ចេញមកមានចង្វាក់យឺតៗ ជាសញ្ញាថាការភ័យខ្លាចលើកនេះដល់កម្រិតកំពូលហើយ។

គ្រប់យ៉ាងជុំវិញខ្លួនហាក់ស្ងៀមស្ងាត់ឈឹង។ ខ្ញុំដឹងច្បាស់ខ្លួនឯងថា មិនអាចរង់ចាំក្នុងការ និយាយរឿងយល់សប្តិចម្លែកនោះប្រាប់គេឯងទេ គឺឱ្យតែបេះដូងដើរស្រួលបន្តិចនឹងអាលចេញទៅតាមបងឌីនមកនិយាយគ្នាភ្លាម។

បង្អួចនៅចំហៀងដៃខ្ញុំ ស្រាប់តែចំហចុះឡើង ព្រោះមានកម្លាំងខ្យល់ចូលមកវ្ញៗដូចមេឃខាងក្រៅរកកលនឹងភ្លៀងធំ។

ខ្ញុំនឹកឃើញភ្លែតដល់ខោអាវដែលហាលនៅខាងក្រោមកណ្តាលបរិវេណដី។ ដូច្នេះ ខ្ញុំបានច្រត់ដៃក្រោក ហើយដើរសំដៅទៅពិនិត្យតើភ្លៀងធ្លាក់មែនឬអី?

ទោះទីនេះមិនមានពន្លឺជួយ តែខ្ញុំចំណាំទ្រង់ទ្រាយបន្ទប់បាន ហើយឈានទៅរកបង្អួចមិនពិបាកបន្តិចណាឡើយ។

ផ្ទុយពីការគិតរបស់ខ្ញុំ នៅក្រៅបង្អួចនោះ ពុំមែនជាបរិវេណដីដែលខ្ញុំបានគិតទុកទេ បែរជា ទ្វារមួយផ្សេងចូលទៅកាន់ផ្ទះមួយទៀត។

ពីកន្លែងខ្ញុំឈរនេះ គឺនៅទល់មុខគ្នាមើលឃើញគ្រប់យ៉ាងដែលកំពុងកើតឡើងក្នុងផ្ទះនោះយ៉ាងច្បាស់។

វាជាផ្ទះថ្មបុរាណពណ៌លឿងក្នុងស្ថាបត្យកម្មទំហំធំមួយ។

ចម្លាក់ក្បូរក្បាច់បង្ហាញពីរចនាប័ទ្មជំនាន់បារាំងដ៏ល្អវិចិត្រ។

វត្ថុមានតម្លៃ ហើយបុរាណ សមជាសម្បត្តិនៃពួកគហបតីជំនាន់ដើមតាំងលម្អក្នុងបន្ទប់នោះ។

មនុស្សជាច្រើនស្លៀកពាក់ខោអាវអំពីសូត្រឆើតឆាយ តែក្នុងរចនាប័ទ្មតុបតែងបែបសម័យអាណានិគម។

ពួកគេហាក់សប្បាយរីករាយ ដូចជាគេហដ្ឋានមួយនេះកំពុងប្រារព្ធកម្មវិធីជាសិរីរុងរឿងណាមួយក្រោមពន្លឺភ្លើងអគ្គិសនីភ្លឺចិញ្ចាច។

ហេតុអ្វីគេធ្វើពិធីទាំងកណ្តាលយប់? ម៉េចក៏កន្លែងខ្ញុំនេះងងឹត រីឯកន្លែងពួកគេភ្លឺ? ហេតុអ្វីខ្ញុំមើលឃើញពួកគេច្បាស់ តែមិនអាចស្តាប់ឮអ្វីលាន់ចេញពីផ្ទះមួយនោះបាន?

សំខាន់ ខ្ញុំមិនដែលដឹងថា ជាប់របងដីខ្ញុំមានផ្ទះស្កុកស្កម្ភមួយនេះសោះ?

នៅពេលនេះ ខ្ញុំមានអារម្មណ៍ដូចជាឃើញគេដឹកដៃកូនក្រមុំចេញមករៀបការ ហើយនាងមិនព្រមនាងយំ។

ខ្ញុំឃើញនាងហូរឈាមតាមភ្នែក ប៉ុន្តែនាងនៅតែជាកូនក្រមុំដ៏ស្រស់ស្អាត។

សាជាថ្មី ខ្ញុំដឹងថានេះមិនមែនជាការពិតទេ វាជាការយល់សប្តិត្រួតលើយល់សប្តិ ប៉ុន្តែខ្ញុំហាក់មិនភ័យខ្លាចច្រើនជាងការចង់ដឹងឡើយ។

ខ្ញុំបានឈានចូលកាន់តែកៀក ហើយក្រឡេកទៅមើលពួកមនុស្សដែលនិយាយខ្សឹបខ្សៀវសើចចំអក។ ស្រាប់តែខ្ញុំឃើញដើមឈើមួយនៅក្បែរបង្អួចខ្ញុំ បន្ទាប់មកនារីនោះបានឡើងមកដល់ ហើយចាប់ផ្តើមអង្គុយលើមែកដ៏ធំមួយ។

ដូចក្នុងភាពយន្តរឿងអាគាំង នាងស្រាប់តែធ្វើមុខសាហាវឃោរឃៅ ហើយលើកកាំបិតមកចាក់ទ្រូងខ្លួនឯងភឹប។

ខ្ញុំភ្លឹកសម្លឹងដើមឈើនោះ និងកូនក្រមុំដែលផ្អែកកាយស្លាប់ម្នាក់ឯងគ្មានអ្នកណារវីរវល់។ក្នុងអារម្មណ៍ខ្ញុំ នាងស្លាប់ហើយ។

ខ្ញុំឃើញនាងកាន់ចបមួយនៅលើដៃ។ ច្បាស់ណាស់ មុននេះខ្ញុំមិនឃើញអ្វីទេ តែពេលនេះខ្ញុំឃើញចប??????

ហេតុអ្វីនាងចាំបាច់កាន់វាឡើងទៅសម្លាប់ខ្លួនលើដើមឈើ។ តើនេះជាអ្វី? វាជាសញ្ញាអ្វីដែលនាងចង់ប្រាប់?

ផ្អើលព្រុសរំពង។

ខ្ញុំងាកមកវិញ ហើយដួលព្រុសមិនដឹងខ្លួនទៀត។

ពេលបើកភ្នែកឡើងមកវិញ ហើយឃើញដំបូលផ្ទះនៃបន្ទប់ខ្លួនឯង។

ខ្ញុំដឹងខ្លួនហើយ! ខ្ញុំបានដឹងខ្លួនពិតមែន គ្រប់យ៉ាងមិនបានស្ថិតក្នុងសុបិនទៀតនោះទេព្រោះខ្ញុំឮសំឡេងប្រពន្ធខ្ញុំ និងភរិយាបងឱននិយាយគ្នាសើចខឹកៗមកពីជាន់ក្រោម។

ខ្ញុំរិលរវល់?

ម៉េចក៏ខ្ញុំឡើងដេកលើផ្ទះ?

នៅលើតុកំព្យូទ័រ ខ្ញុំដេកស្មៀមឈឺង?

ខ្ញុំមានតែជ្រប់មុខរម្លឹកឡើងវិញ មួយណាជាការពិត ហើយមួយណាជាយល់សប្តិ។

នាឡិកាទូរសព្ទខ្ញុំប្រាប់ថាពេលនេះម៉ោង ៧ យប់ហើយ។

អាកាសធាតុត្រជាក់មានជាតិសំណើមហាក់មុននេះពិតជាមានភ្លៀង?

ខ្ញុំវិញស្វាងចៃសដូចបានដេកឆ្អែតណាស់អ៊ីចឹង។

សាជាថ្មី ងាករកបង្អួច ហើយក្រោកដើរទៅទីនោះសម្លឹងទៅខាងក្រៅ។ ទោះយ៉ាងណា ដើងមេឃខាងក្រៅនៅសល់ស្រមោលក្រហមព្រាលៗ។

ថ្ងៃទើបនឹងលិចទេ ខ្ញុំដេកសាហាវយ៉ាងនេះ យល់សប្តិអាក្រក់បែបនេះ?

ពីក្រោយបង្អួចបន្ទប់ខ្ញុំ វាគ្មានផ្ទះអ្នកមានកាលពីសម័យបុរាណ និងពិធីរៀបការមង្គលការស្អីទាំងអស់។ នៅជាន់ខាងក្រោម បងឌីនកំពុងតែកាប់ទឹកកកលើគ្រែឫស្សី មានអំពូលតូចពងមាន់ដែលតដាក់ក្រោមដើមក្រខុបកំដរគាត់។

គ្រប់គ្នាគេកំពុងត្រៀមសម្រាប់អាហារល្ងាចជួបជុំនេះ ខ្ញុំគួរលាក់ទុកសុបិននេះតែម្នាក់ឯង។ ខ្ញុំចេញពីបន្ទប់លុបមុខ ហើយចុះទៅដើរចរច្រប់ក្បែរបងឌីន។

ម្តងៗ ខ្ញុំលួចសម្លឹងទៅម្តុំខាងក្រោយដែលរោងមួយនោះនៅស្ងៀមស្ងាត់ងងឹតស្លុប។

ក្រឡេកបានពីរដងប៉ុណ្ណោះ អ្វីមួយនៅទីនោះទាក់ភ្នែកខ្ញុំឱ្យដកចេញលែងបាន។

ចបកាប់?

សុបិនមុននេះបានបង្ហាញពីចបកាប់មួយដែលនាងកាន់ជាប់ដៃមុនស្លាប់?

កូនក្រមុំចម្លែកនោះចង់ប្រាប់អ្វីដល់ខ្ញុំទៅ?

ខ្ញុំសម្លឹងទៅបងឌីនមើលលេងៗ ព្រោះ...ហើយចុងក្រោយ ខ្ញុំមិនអាចទប់ចិត្តបាន ក៏បបួលគាត់ខ្សឹប។

«បងឯងទៅណោះមើលជាមួយខ្ញុំ!»

ខ្ញុំចង្អុលទៅចបមួយដែលផ្អែកក្បែរបាវដី និងគំនរ បងឌីនក៏សម្លឹងទៅកាន់ទីនោះដូចគ្នា។ ខ្ញុំសម្គាល់អ្វីៗបានច្បាស់តាំងពីចម្ងាយ ប៉ុន្តែហេតុអ្វីបានជាបងឌីនចាំបាច់ចុចពិលពីទូរសព្ទគាត់?

អូមែនហើយ មកពីខ្ញុំបានយល់សប្តិ ចំណែកគាត់មិនដឹងអីទាំងអស់!

ខ្ញុំរត់ទៅកាន់ទីនោះមុន ហើយឈប់ទ្រឹងចម្ងាយប្រមាណជា ៤ ម៉ែត្រពីម្តុំបាវដីអស់នោះ។ ជាមួយកម្លាំងពិលរបស់គាត់ និងភ្លើងជះមកពីផ្ទះបាយ ខ្ញុំរវើរវាយសម្លឹងគ្រប់យ៉ាងជុំវិញឃ្លាំង ក្នុងអារម្មណ៍សែនខុសប្លែកពីសព្វមួយដង។ ចបនោះ និងរូបភាពនារីបុរាណដែលធ្វើអត្តឃាតខ្លួនឯងក្បែរបង្គួចហាក់មានតម្រុយថាប្រទាក់ក្រឡាគ្នាច្បាស់ណាស់ ទោះបីមួយជាជីវិតពិត មួយទៀតជាយល់សប្តិ។

«នាងចង់ប្រាប់ខ្ញុំពីរឿងអ្វី? »

ខ្ញុំគិតហើយ នៅទ្រឹង ជើងមិនទាន់ដើរទៅដល់ចបនោះនៅឡើយ។ ខ្ញុំដឹងថាបងឌីនកំពុងដើរមកតាមពីក្រោយខ្ញុំយឺតៗដែរ។

តើស្អីទៅបណ្តាលចិត្តខ្ញុំឱ្យមកឈរភ្លឹកនៅទីនេះ?

ខ្ញុំងាកទៅឃើញបងឌីនមកដល់ចម្ងាយប្រហែលជា ៣ ម៉ែត្រពីគ្នា។

«ឯងរកស្អីឯង ចន្ថា?»

បងឌីនសួរ ហើយដៃគាត់រុញពិលចុះឡើងៗទៅរកគោលដៅផ្សេងគ្នា។ គាត់មិនបានចាប់អារម្មណ៍អ្វីនឹងចបមួយនោះទេ។

«អត់អីទេ ចាំស្អែកទៅ!»

មិនដឹងដែរ មិនដឹងអ្នកណា ឬអំណាចអ្វីទេដែលនាំឱ្យខ្ញុំឆ្លើយលឿន ហើយខ្លីបែបនេះ?

ខ្ញុំដឹងថាគាត់ហេវ ហើយមិនយល់អីទាំងអស់។

«តោះទៅហូបបាយវិញ!»

ខ្ញុំមកក្រៀកគាត់ដើរត្រឡប់ទៅផ្ទះវិញ។

ទោះយ៉ាងណា ពេលនេះយប់ហើយ ខ្ញុំមិនអាចធ្វើអ្វីទាំងយប់ទេ ហើយរឿងយល់សប្តិមិញនោះទៀតសោត ក៏មិនដឹងថាត្រូវពន្យល់បងប្រុសខ្ញុំពីណាទៅណាដែរ។ ពួកយើងដើរត្រឡប់ក្រោយទាំងក្នុងចិត្តខ្ញុំបែរបន់សុំក្តីសុខ។

ជាមួយនោះ ខ្ញុំជឿថា អ្វីមួយមានវិញ្ញាណកំពុងតាមសម្លឹងបងប្អូនខ្ញុំពីក្រោយខ្នង។

**វគ្គ**

**កូនក្រមុំជំនាន់បារាំង**

ពួកយើងរៀបចំការហូបចុក ខ្ញុំក៏យកបាយទឹកមួយចំណែកដាក់សែនចោលនៅលើដីក្បែររានទេវតា ហើយបួងសួងបន់ស្រន់។

ខ្ញុំដឹងថា សកម្មភាពខ្ញុំបានធ្វើឱ្យបងឌីនចាប់អារម្មណ៍។

អ៊ីចឹងហើយបានជាព្រលឹមមិនទាន់ ខ្ញុំមើលពីលើទៅក្រោមឃើញគាត់ទៅឈរក្បែរឃ្លាំងហើយសម្លឹងសម្លក់។

ខ្ញុំចុះដីឃើញណានីនប្រពន្ធខ្ញុំនៅពកូនបញ្ចុកបាយ ចំណែកប្រពន្ធបងឌីនលាងជម្រះទីកន្លែងយើងហូបចុកកាលពីយប់។

«អាដូច ចាំបងជួយរើសម្អាតឃ្លាំងនេះឱ្យ!»

គាត់និយាយទាំងមិនបែរក្រោយ ហើយជើងគាត់ទាត់បំបើុងដុំឥដ្ឋតូចៗឱ្យខ្ទាតចេញពីផ្លូវទៅកាន់មុំកៀនៗរបង។

ខ្ញុំឱនទៅលើកកូនពីដៃប្រពន្ធមកបីថើប តែចិត្តនៅមិនស្រណុកទេ។

យប់មិញកណ្ដាលអធ្រាតខ្ញុំលបលេបថ្នាំងងុយមួយគ្រាប់ ទើបដេកបាន។

ចិត្តខ្ញុំមិនស្រួលសោះ តែខ្ញុំមិនចង់និយាយ។

«បងឯងមកលេងពីរបីថ្ងៃ ធ្វើការអីធ្វើម៉េះបង?»

ណានីនឃាត់មិនចង់ឱ្យបងឌីនរវល់។

ខ្ញុំងាកទៅរកបងខ្ញុំ បន្ទាប់មកក៏ឃើញគាត់ឈប់ជើងឱនសម្លឹងអ្វីម្យ៉ាងលើដី ហើយគាត់ចាប់ផ្ដើមទាត់ម្ដងទៀត។ គ្មានឥដ្ឋមួយដុំណាប៉ើងមកទេ។ ដូច្នេះ បងឌីនឱនពិនិត្យទៀត។ អាការៈគាត់ទំនងដូចជាប្រទះឃើញអ្វីម្យ៉ាងមិនប្រក្រតី ទើបគាត់ស្រែកប្រកូកហៅខ្ញុំ៖

«ចន្ថា មកមើលស្អីគេនៀក?»

ខ្ញុំដើរមួយៗត្រឡប់ទៅរកគាត់។ ក្រោមជើងគាត់ តាមពិតជាបន្ទះឥដ្ឋរឹងដែលទាត់ច្រើនដងយ៉ាងណា ហើយនៅតែមិនរង្គើខ្ទាតទៅណាសោះ។ ខ្ញុំសម្លឹងដោយចាប់ផ្ដើមមានអារម្មណ៍ប្លែកៗម៉េចមិនដឹង។ វាទំនងជាបំណែកណាមួយនៃមាត់ពាង?

បងឌីន គាត់ឱនទៅកាយមើល បង្ហាញថាគាត់ក៏កំពុងគិតឃើញដូចខ្ញុំ? ចំមែន! វាមិនមែនជាបំណែកទេ តែជាមាត់ពាងទាំងមូលតែម្តង។

មិនយូរប៉ុន្មាន អ្វីមួយមានសណ្ឋានដូចជាគម្របក៏ត្រូវបានលេចមកច្បាស់ៗឡើងក្រោមការឈ្វេកកកាយញាប់ដៃរបស់ពីរនាក់ខ្ញុំ។

ពួកខ្ញុំងាកមើលមុខគ្នា!

ការកប់ពាងក្នុងដីជារឿងដែលខ្ញុំធ្លាប់តែឮចាស់ៗតំណាលមក តែមិនដែលបានឃើញផ្ទាល់ភ្នែកអ៊ីចឹងម្តងណាឡើយ។

ម៉ែតែងប្រាប់ថា ដោយសារស្រុកយើងឆ្លងកាត់សង្គ្រាមច្រើន អ្នកស្រុកតែងតែនិយមធ្វើពាងតូចៗដើម្បីកប់ទុកទ្រព្យសម្បត្តិសំខាន់ៗ។ ទីដែលពួកគេកប់ ច្រើនតែចំណាំធ្វើនៅជើងសសរ ដើមឈើ កាំជណ្តើរ។ល។

ចង់បកស្រាយថា នារីជំនាន់មុនកាលពីយប់មិញបានពន្យល់សប្តិប្រាប់ខ្ញុំអំពីពាងមែនឬអ្វី? ហេតុអ្វីបានជានាងរើសយកខ្ញុំ? នាងចង់ឱ្យខ្ញុំធ្វើម៉េចចំពោះរបស់នេះ? ក្នុងនេះមានអ្វីខ្លះទៅ?

ជាការពិត ទោះបីជាមានសំណួរមិនចេះអស់មិនចេះហើយលេចចេញមកក្នុងពេលដំណាលគ្នា ក៏ប៉ុន្តែខ្ញុំគ្មានកូនចិត្តអ្វីបន្តិចចំពោះរឿងកំណប់ជាមាសពេជ្រមានតម្លៃ។ ករណីរបស់បងសារ៉ាយ និងឪពុកក្មេកខ្ញុំ ជារឿងដែលខ្ញុំល្មមចងចាំបង្រៀនខ្លួនឯងពេញមួយជីវិតនេះថា កុំឱ្យចង់បានអ្វីមួយដែលពុំមែនជាកម្មសិទ្ធិរបស់យើង។

«រឹងដល់ហើយវ៉ី ចន្ថា! កាយមិនចេញទេ! រកអីគាស់!»

បងឌីនលែងប្រើដៃកកាយបានទៀតហើយ។ ខ្ញុំក្រឡេកជុំវិញខ្លួន ចុងក្រោយភ្នែកទើរនឹងចបដែលផ្អែកចោលក្បែរគំនរបាវទាំងនោះ។

ខ្ញុំប្រើម្រាមចង្អុលសួរបងឌីនស្ងាត់ៗ គាត់ងក់ក្បាល ហើយឈរដំអក់រង់ចាំខ្ញុំដែលរត់ទៅរើសចបនោះយកមកឱ្យ។

បងឌីនចាប់ផ្តើមកាប់ដីក្បែរៗជុំវិញពាងនោះលុងមើលសណ្ឋានរបស់វា។ ស្ថានភាពគម្របពាងបង្ហាញថារាងពិតរបស់ពាងទាំងមូលមិនមែនធំលើសនេះដល់ទៅពីរដងទេ គឺបងឌីនគាត់កាប់ស្ទាបស្ទង់មើលប៉ុណ្ណោះ។

ចិត្តខ្ញុំជ្រួលច្រាលអន្ទះសា ស្រាប់តែគាត់ឈប់ដៃ។

«បងឯងឈប់ធ្វើអី?»

គាត់គិតបន្តិច ជូតញើស ហើយទើបឆ្លើយ៖

«ដូចធ្លាប់ឮចាស់ៗនិយាយថារបស់កប់ចោលយូរ គេមានបាលី មុនជីកយក!»

ខ្ញុំនៅស្ងៀមគាំងយោបល់។

បងឱនដាក់ចបចុះ ហើយទូរសព្ទទៅស្រុករកពុក និងម៉ែ។

បន្តិចក្រោយមក គាត់ដើរមកនិយាយនឹងខ្ញុំឱ្យរកចាស់ៗក្នុងភូមិមកគិតរឿងពាងនេះ គាត់មិនហ៊ានគាស់ទៀតទេ។

ខ្ញុំនឹកឃើញដល់អ៊ំមួយឈ្មោះ គង់ ជាអ្នកជិតខាងស្លូតបូតម្នាក់ដែលខ្ញុំជិះកាត់មុខផ្ទះគាត់កាលណា គាត់តែងញញឹមដាក់។ ខ្ញុំដាច់ចិត្តនាំបងខ្ញុំទៅជួបគាត់តែម្តង។

ថៃដន្យគាត់កំពុងហូបបាយព្រឹក ខ្ញុំ និងបងចូលសំពះសុំនិយាយសួរនាំគាត់៖

«អ៊ំ! អ៊ំដែលស្គាល់អ្នកជួលផ្ទះនៅទីនេះមុនខ្ញុំ ដែរអត់?»

គាត់ធ្វើញឹមៗសម្លឹងមុខខ្ញុំ ហើយបបួលចូលអង្គុយលេងក្នុងផ្ទះសិន។ ខ្ញុំដឹងថាគាត់ប្រាកដជាដឹងរឿងអ្វីមួយទាក់ទងនឹងផ្ទះនេះជាក់ជាមិនខាន ដូច្នេះហើយបានជាខ្ញុំក៏ព្រមទៅតាមគាត់។

«ក្មួយឯងត្រូវខ្មោចលងមែនអត់?»

គាត់សួរមកចំៗអ៊ីចឹងទៀត ធ្វើឱ្យចិត្តខ្ញុំកាន់តែវិលវល់ ហើយមិនដឹងត្រូវឆ្លើយអ្វី មានតែនៅស្ងៀមទុកជាការសារភាព។ ឃើញដូច្នេះ អ៊ំគង់និយាយបន្ថែម៖

«កាលខ្ញុំមកនៅផ្ទះនោះដំបូង ក៏ដូចក្មួយឯងអ៊ីចឹង បានជាខ្ញុំដូរមកនៅដីតូចជាងមុនវិញ ព្រោះខាងណេះសុខជាង!»

ខ្ញុំទើបនឹងដឹងថា តាមពិតអ៊ំគង់នេះជាម្ចាស់ដីនោះតាំងពីស្រុកទើបនឹងមានសន្តិភាព។ គាត់អះអាងថាគាត់នៅបានមិនដល់មួយខែទេ ក៏បានរើចេញមកនៅខាងនេះវិញ សុខចិត្តចោលដីធំយកដីតូច។

គាត់និយាយបន្ថែម ពេលដែលភរិយាគាត់ដើរមកជិត៖

«ប្រពន្ធខ្ញុំនេះទេដែលជាអ្នកឃើញរឿងប្លែកៗ គាត់នៅមិនបាន បានជាខ្ញុំព្រមតាមគាត់ រើចេញមកដូរកន្លែង! ចំណែកខ្ញុំ ខ្មោចវាមិនហ៊ានជាមួយទេ! ក្រៅពីប្រពន្ធស្រែកស្លុតយប់ព្រលប់នៅមិនបាន គេងមិនសុខ ខ្ញុំមិនដែលឃើញស្អីទាំងអស់!»

ខ្ញុំងាកទៅសម្លឹងមុខអ៊ំស្រីដែលជាភរិយាគាត់។ ទឹកមុខអ៊ំមិនមានអ្វីបង្ហាញថា គាត់បដិសេធសម្តីរបស់ប្តីនោះឡើយ។ គាត់ទំនងជាយល់សប្តិអាក្រក់ ឬឃើញ និងឮរឿងប្លែកៗ ដូចស្ថានភាពរបស់ខ្ញុំនេះដែរហើយ បានជាសម្រេចចិត្តលែងនៅលើដីនោះ?

«អ៊ំស្រីធ្លាប់យល់សប្តិឃើញអី?»

ខ្ញុំសួរព្រោះចង់ដឹងរឿងរ៉ាវឱ្យបានច្បាស់។

ភរិយាអ៊ំគង់និយាយឡើងភ្លាម៖

«រឿងកើតឡើងយូរហើយក្មួយអើយ! អ៊ំនេះជាមនុស្សមានក្រយៅខ្មោចលង ទៅណាមកណាមិនស្រួលៗតែងតែមើលឃើញអ្វីដែលប្តីអ៊ំមិនដែលឃើញ!»

ខ្ញុំគិតថាគាត់មានរឿងច្រើនចង់និយាយជាមួយខ្ញុំ និងបងឌីន ប៉ុន្តែពេលនេះខ្ញុំគិតដល់រឿងពាងនោះមុន ទើបកាត់គាត់ថា៖

«អ៊ំអើយ ខ្ញុំមានរឿងចង់ពិគ្រោះ គឺខ្ញុំឃើញពាងមួយកប់ក្នុងដី តែមិនដឹងត្រូវធ្វើម៉េច? បងខ្ញុំទូរសព្ទទៅផ្ទះ ម៉ែគាត់ឱ្យរកចាស់ទុំអ្នកស្រុកឱ្យជួយគិត គាត់មិនចង់ឱ្យរើភ្លាមៗទេ! អ្នកស្រុកខ្ញុំគេមានគ្រូណាមច្រើនណាស់!»

ឮហើយ អ៊ំគង់គិតចុះឡើង ក៏គាត់ឱ្យយោបល់ថាគួរទៅនិយាយនឹងចាស់ៗពីរបីគ្រួសារទៀត។

មនុស្សបួនប្រាំនាក់បានមកដល់ផ្ទះខ្ញុំនៅពេលថ្ងៃត្រង់។

អ៊ំម្នាក់គេហៅគាត់ថាអ៊ំខួច គាត់ឃើញរបស់ ហើយគាត់ពិនិត្យយូរក្រៃលមុនពេលងាកមកខ្សឹបសួរខ្ញុំ៖

«ពីណារកឃើញ?»

ខ្ញុំមិនមាត់តែចង្អុលទៅរកបងឌីន។

បងឌីនឱនបារកាយដី។

អ៊ំគង់និយាយនឹងលោកតាអាចារ្យចំណាស់ម្នាក់គ្នាគាត់រអ៊ុះៗ។

បន្ទាប់មក ពួកគេបានមកជួយកាប់តិចៗកម្ទាយដីដ៏រឹងនោះចេញម្ដងមួយចំណែកៗ។ ខ្ញុំក៏បានឮសូរអ្នកដែលឈរនៅពីក្រោយខ្នងខ្ញុំ សូត្រធម៌សុំម្ចាស់ទឹកម្ចាស់ដីរងំបន្តគ្នា។ ខ្ញុំមិនបាច់ងាកទេ ព្រោះការគោរពតាមទម្លាប់អ្នកស្រុកជារឿងគួរឱ្យកក់ក្ដៅជាជាងប្រថុយប្រថាន។

ពេលដែលពាងលេចរូបរាងកាន់តែច្បាស់ ហើយដោយសារគម្របវាត្រូវបានបិទជិតដោយប្រុងប្រយត្ន័ផង ខ្ញុំស្រមៃថា ក្នុងនោះជាគ្រឿងអលង្ការបុរាណ។ មួយរយភាគរយវាជាកំណប់ដែលអ្នកជំនាន់មុនបានលាក់ទុកមក ហើយក្រោយមកទំនងជាបាត់ដានព្រោះដីរំកិលដូចករណីពុកក្មេកខ្ញុំ។

«ធ្ងន់ណាស់!»

បងខ្ញុំនិយាយ ហើយចាស់ៗក៏លូកដៃទៅប្រុងជួយរំកិលពាងជាមួយគាត់។ នោះជាកូនពាងដែលមានទំហំប៉ុនមួយឱបកូនក្មេងប៉ុណ្ណោះ ចុះហេតុអ្វីក៏ធ្ងន់ម្ល៉េះ? អ្នកណាម្នាក់កេះដៃកកេះឆាច់ ពេលខ្ញុំប្រុងឱនទៅជួយលើកបងខឺន។

«ឈប់! អុជធូបសិន!»

ពីនាក់បងប្អូនខ្ញុំដកដៃមកវិញទុកឱ្យចាស់ៗអុជធូប។ សំឡេងអ៊ំស្រីប្រពន្ធអ៊ំគង់និយាយបង្គាប់ប្រាប់ពីក្រោយខ្នងខ្ញុំ៖

«ពាងនេះមិនមែនកប់មកថ្មីៗទេ! មើលបាលីនៅលើនោះចុះ!»

ខ្ញុំចំហមាត់សម្លឹងតាមចង្អុលដៃគាត់។ អក្សរបុរាណតូចៗល្អិតបិទលើភ្នាសឈើប្រវែងប្រមាណពីម្រាមដៃមនុស្សចាស់ភ្ជាប់ជាមួយនឹងគម្របពាងដោយខូងចូលជ្រៅទៅក្នុងសាច់ថ្ម។ ឈើបន្ទះសាងពីអ្វីម្ដេចក៏មិនខូចរូបរាង?

សំឡេងលោកអាចារ្យលាន់ឡើងនិយាយបន្ថែម៖

«កុំប៉ះពាល់ផ្ដេសផ្ដាស!»

គាត់ចាប់ផ្ដើមដើរទៅដងទឹកផ្ដិលមកស្រោចជុំវិញបីជុំ ហើយសូត្រមន្តជីបអូច បន្ទាប់មកក៏យកធូបដែលតាម្នាក់ឈ្មោះខួចជាគ្នាគាត់បានអុជរង់ចាំនោះ ទៅដោតលើដីក្បែរមាត់ពាង។

«ចម្លែកដល់ហើយ ដីប៉ុណ្ណឹងធ្ងន់ម្ល៉េះ?»

តានិយាយ ចំណែកអ៊ំខួចគិតពីសូត្រធម៌។ រង់ចាំដល់ធូបឆេះអស់ ទើបគេចាប់ផ្តើមបបួលគ្នាលើក ប៉ុន្តែលើកយ៉ាងណា ក៏មិនចេះរួចសោះ។

ទាល់តម្រិះ លោកយាយក៏ប្រាប់ទៅបងឌីនៈ

«ឯងជាអ្នកឃើញ លើកឡើងសាកមើលទៅ!»

បងឌីន និងប្រពន្ធមុខស្លេកងាំង។ ចិត្តគាត់គិតយ៉ាងណាចំពោះរបស់កំណប់នេះគ្មានអ្នកណាស្មាន ដល់ទេ តែគាត់បង្ហាញអាការៈហាក់ទីមទើម ព្រោះគាត់យល់ថា គាត់ម្នាក់ឯងម៉េចនឹងអាចលើករួច? លោកអាចារ្យឱ្យធូបមួយសរសៃទៀតមកគាត់ដុត ហើយឱ្យបួងសួងសុំលើកវា។ ទីបំផុត គាត់នៅតែ លើកមិនរួចដដែល។

«ខ្ញុំសុំលើក! ខ្ញុំដឹងថា អ្នកណាជាអ្នកឱ្យខ្ញុំមកលើករបស់នេះ!»

គ្រប់គ្នាសម្លឹងមកខ្ញុំ។ ដោយមិនចង់ឱ្យខាតពេល ខ្ញុំក៏និយាយបង្ហើយៈ

«ខ្ញុំយល់សប្តិឃើញនាងពីរដងជាប់គ្នា! នាងមានសម្លៀកបំពាក់ជាកូនក្រមុំសម័យបារាំង! ខ្ញុំឃើញ ចប នៅពេលដែលនាងស្លាប់! ខ្ញុំក្រោកមកមើល ក៏ឃើញចបមែន បានជាហៅបងខ្ញុំមកមើលជាមួយ គ្នា! ពេលគាត់ដើរមក ក៏ជាន់មាត់ពាងនេះ! វាមិនមែនចៃដន្យទេ! ខ្ញុំមកនៅកន្លែងនេះច្រើនថ្ងៃដែរ ហើយ ម៉េចក៏មិនបានឃើញវា?»

«លើកចុះ!»

ខ្ញុំបានការអនុញ្ញាតពីតាអាចារ្យ ក៏ងាកទៅសម្លឹងមុខអ៊ំគង់ និងភរិយា ដឹងអីពួកគាត់ក៏ងក់ក្បាលយល់ ព្រមទៀត ដូច្នេះខ្ញុំឱនលើក។ ពាងនេះនៅតែធ្ងន់ដដែល មិនរំកិលសូម្បីតែបន្តិចណា។ កន្លែងណា មួយក៏មិនកម្រើករង្គើ ខ្ញុំគិតថាមានអ្វីម្យ៉ាងជាប់ស្អិតនៅបាតវាផងក៏មិនដឹង?

«បងឌីនមកជួយលើកខ្ញុំមកបង!»

គាត់ឆ្លើយ «អើ!» ហើយឱនមកជួយគ្នា។ តែមួយព្រឹបសោះ ខ្ញុំលើកពាងហើបមកបានពាក់កណ្តាល ធ្វើឱ្យគ្រប់គ្នាលើកដៃមកជួយ។

ចុងក្រោយរបស់បានដាក់មកលើដីក្រោមការតាមដានរបស់គ្រប់គ្នាមិនហ៊ានប្រិច។ គ្មានអ្នកណាយ កចិត្តទុកដាក់នឹងបាត់ដីខាងក្រោមពាងទេ?

ពេលពួកគេសែងពាងនោះទៅក្រោមដើមឈើក្បែររានទេវតា ហើយប្រហែលជាដាក់ចេកអុជធូបបន់ទៀត។

បងឌីនលូកដៃទៅយកអ្វីម្យ៉ាងមកបង្ហាញខ្ញុំ។

វាដូចជាស្បែកសត្វមើលពីដំបូង តែមើលយូរទៅជាក្របសៀវភៅធ្វើពីស្បែកសត្វ។

សៀវភៅនេះមានបិទឡេវ តែមានចន្លោះដែលទឹកអាចជ្រាបចូលបាន សំណាងដែលនៅបាតនោះគ្មានប្រភពទឹកចូលដល់ ដូច្នេះទោះបីវាចាស់ ប៉ុន្តែមិនបានរលួយបង់រហែកទេ។

ខ្ញុំទទួលពេលបងឌីនហុចមកឱ្យ។ ព្រោះគាត់មិនចេះអក្សរទេ ខ្ញុំដឹង។ ខ្ញុំថយទៅម្ខាងឆ្ងាយពីគេ ហើយអង្គុយបើកវាមកអាន។

បងឌីននៅមើលពាងជាមួយគេឯង។

របស់ក្នុងដៃខ្ញុំប្រើអក្សរបារាំងទាំងអស់។

ហេតុអ្វីម្ចាស់សៀវភៅរៀនមិនសរសេរភាសាខ្មែរ?

ខ្ញុំអានវាតាមការអន្ទះសាចង់ដឹងរបស់ខ្ញុំ។

«ខ្ញុំឈ្មោះរឿង ជាឈ្មោះផ្កាម្យ៉ាងមានពណ៌លឿង! នៅស្រុកខ្មែរ គេហៅវាថាស្បៃរឿង ហើយគេនិយមណាស់សម្រាប់ពិធីបូជាផ្សេងៗ! ពេលដែលអ្នកឃើញសៀវភៅនេះ ខ្ញុំស្លាប់បាត់ទៅហើយ ព្រោះតែខ្ញុំតាំងចិត្តមិនព្រមរៀបការជាមួយម៉ឺនម្នាក់ឈ្មោះតៃ ដែលពុកបានផ្សំផ្គុំឱ្យ! ខ្ញុំចេញទៅរៀននៅស្រុកបារាំងពេលអាយុបាន ១៦ ឆ្នាំ ហើយខ្ញុំបានស្គាល់បុរសម្នាក់ឈ្មោះងារ ជាខ្មែរមកពីតំបន់ខាងត្បូង! គាត់គួរឱ្យទុកចិត្តបាន ហើយយើងបានផ្តោះប្តូរស្នេហាជាមួយគ្នា! យប់នេះ ខ្ញុំដឹងថា ខ្ញុំនិងងារមិនអាចជួបគ្នាជាស្វាមីភរិយាបាន ដោយសារតែពាក្យសន្យារបស់ពុក និងគ្រួសារម៉ឺនតៃ! ម៉ឺនតៃមានទំនាក់ទំនងជាមួយប្រពន្ធចុងពុក គាត់មិនស្តាប់ចិត្តកូនទេ ថែមទាំងធ្វើកាចសាហាវដាក់កូនស្រី! ខ្ញុំបានសម្រេចចិត្តលួចរត់ទៅរកងារ ហើយនាំទៅជាមួយពូព្រឹក និងលោកយាយមេដោះផង។ ពុកបានតាមទាន់ចាប់ពួកគាត់វាយដំដាក់ច្រវាក់បង្អត់បាយ! ពុកនឹងធ្វើទោសអ្នកបម្រើដល់ស្លាប់ បើខ្ញុំមិនព្រមរៀបការ!»

ខ្ញុំស្លុតចិត្ត ហើយឈប់អាន។

ចិត្តមួយនឹកដល់អ្វីៗដែលបានឃើញក្នុងសុបិនកាលពីយប់ ចិត្តមួយចង់ដឹងជក់ចិត្តនឹងរឿងរ៉ាវបន្ត របស់ម្ចាស់សៀវភៅ។ ខ្ញុំបកទៅរកទំព័រថ្មី។

ចាប់ផ្ដើមទំព័រទីពីរ នាងសរសេរខ្វៀកសឹងថាពិបាកមើលណាស់ មើលមិនចង់ដាច់ទេ។

«មីងៗរត់មកប្រាប់ថា មេដោះឈឺស្លាប់ក្នុងផ្ទះខាងក្រោយបាត់ហើយ! ពុកមិនដែលខ្លាចរាជការ ហើយពុកមិនចេះអាណិតអ្នកណាទាំងអស់! ខ្ញុំគិតថាពូព្រឹកក៏ប្រហែលជាត្រូវគេចាប់ធ្វើបាបដែរ ព្រោះរឿងរបស់ខ្ញុំ បានជាមនុស្សរបស់ខ្ញុំតាមរកពូព្រឹកមិនឃើញ? ពេលនេះ មនុស្សគ្រួសារម៉ឺនតែ បានមកដល់ពេញផ្ទះហើយ តើខ្ញុំគួរធ្វើបែបណា?»

ប្រហែលជាអ្នកណាមកដល់បានជានាងបញ្ឈប់ការសរសេរយ៉ាងខ្លីតក់ក្រហល់។ ខ្ញុំប្រញាប់ស្វែងរក ទំព័រទីបី។

«ងារបានខូចចិត្ត ហើយចូលបម្រើកងទ័ព គេមិនបានសរសេរអ្វីផ្ញើមក តែក៏ផ្ដាំពាក្យតាមមីងៗថា គេលាជារៀងរហូត! ខ្ញុំយំរហូតដល់មិនដឹងថានឹងមានជីវិតរស់ដល់ថ្ងៃស្អែកដែរឬអត់? ខ្ញុំចង់ទៅរកងារ ហើយរត់ទៅស្រុកបារាំងជាមួយគ្នា បំភ្លេចទីនេះ!»

គ្មានអក្សរទៀតទេ! មានតែប៉ុន្មានទំព័រនេះ ទោះសៀវភៅក្រាស់កម្រិតណាក្ដី។

ខ្ញុំងើបមុខសម្លឹងទៅរោងឃ្លាំង និងអន្លង់ដែលបង្កប់ពាងមួយនេះ។ ចិត្តខ្ញុំកើតចេញនូវសំណួរជាច្រើន ព្រោះស្លុងចិត្តទៅក្នុងដំណើររឿងរបស់ម្ចាស់សំណេរ។

ខ្ញុំសួរខ្លួនឯងក្នុងចិត្ត៖

«នាងបានព្រមពាក់ឈុតកូនក្រមុំដើម្បីពួកគេហើយ ក្រោយមកហេតុអីនាងសម្លាប់ខ្លួន?»

ខ្ញុំស្លុតចិត្តញ័រដៃ ព្រោះខ្លួនកំពុងវិលទៅរកអតីតកាលមួយកប់បាត់ទៅក្នុងការពិតដែលបានត្រូវគេរំលងចោលទៅតាមពេលវេលា។ នេះបើយោងតាមការប៉ាន់ស្មានដ៏រន្ធត់របស់ខ្ញុំ គឺប្រសិននាងពិតជាសម្លាប់ខ្លួន ចុះហេតុអ្វីនាងលែងបានសរសេរវាទៀតសូម្បីតែពាក្យផ្ដាំចុងក្រោយ?

«ចន្ទា?»

បងខ្ញុំស្រែកពីរម៉ាត់ខ្លីធ្វើឱ្យចិត្តខ្ញុំស្លុតដូចគេមកកន្ត្រាក់។